# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូស្នួល

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ការអនុវត្តន៍ព្រះរាជក្រម ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអភិវឌ្ឍន៍ហោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនផលដំណាំ
- បានឃើញកិច្ចសន្យាទិញ-លក់និងកិច្ចសន្យាជួលដីសំរាប់ចំការកៅស៊ូស្នួល ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ រវាងរាជរដ្ឋាភិបាល កម្ពុជា និងក្រុមហ៊ុន ស្វីហ្វ៊ីសសស៍ លីមីធីត (Swift Resources Limited)
- តាមសំណើរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ហោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនផលដំណាំ

## ស ម្រេ ច

**មាត្រា ១ :** បញ្ចប់ស្ថានភាពគតិយុត្តិចំការកៅស៊ូស្នួល ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ២ :** ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូស្នួល ទៅឱ្យ ក្រុមហ៊ុន ស្វីហ្វ៍រីសសស៍ លីមីធីត (SWIFT RESOURCES LIMITED) ដើម្បីបន្តគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន ស្វីហ្វ៍រីសសស៍ លីមីធីត (SWIFT RESOURCES LIMITED) ចាប់ពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៣ :** រំសាយក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូស្នួល ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ ៨៥១ អនក្រ-តត ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ត្រង់ចំណុច ៥ នៃមាត្រា ១ រំសាយប្រធានអគ្គនាយកចំការកៅស៊ូស្នួល និង រំសាយមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូស្នួល ចាប់ពីថ្ងៃ ទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៤ :** ផ្ទេរឯកឧត្តម ប៊ិច សុវណ្ណ ប្រធានអគ្គនាយកចំការកៅស៊ូស្នួល ចូលមកបំរើការងារក្នុងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃ ទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៥ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកដោះស្រាយបន្តរាល់បំណុលត្រូវទារ និងត្រូវសង ដែលនៅសេសសល់ទាំងអស់ រវាងចំការកៅស៊ូស្នួល និង បណ្តាក្រុមហ៊ុន ស្ថាប័ននានា និងអតិថិជន និងបន្តស្រាវជ្រាវ និង ប្រមូលចំណូលបានពីការកាប់ដើមកៅស៊ូចាស់ៗដែលមិនត្រូវបានយកទៅប្រើប្រាស់ សំរាប់ការដាំដុះឡើងវិញ ដើម្បីបង់ចូលថវិការដ្ឋ ។

**មាត្រា ៦ :** ចំការកៅស៊ូស្នួលត្រូវប្រគល់ត្រា និងឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងឯកសារក្នុងកុំព្យូទ័រមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក ។

**មាត្រា ៧ :** ថវិកាដែលនៅសល់ក្នុងគណនី និង បេឡា របស់ចំការកៅស៊ូស្នួល ត្រូវផ្ទេរចូលថវិការដ្ឋ ។ បិទរាល់គណនីធនាគារទាំងអស់របស់ចំការកៅស៊ូស្នួល ចាប់ពីថ្ងៃ ទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៨ :** អនុក្រឹត្យលេខ ១៩ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតចំការកៅស៊ូស្នួល ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៩
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ